## ក

# មាតិកា

## I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៨-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២២៥ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ខឹង សំអាន** ពីអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ តាមសំណើរបស់សាមីខ្លួន និង ត្រូវបានតែងតាំងសមាសភាពថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ចំនួន ០២ រូប ២៣៤៧

០៩-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២២៦ ស្តីពី ការតែងតាំងឯកឧត្តម **លាង វ៉ូលាន** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើរដ្ឋលេខាធិការ ២៣៤៨

០៩-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២២៧ ស្តីពី ការតែងតាំងឯកឧត្តម **ស៊ាម សុខអូន** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើរដ្ឋលេខាធិការ ២៣៤៩

០៩-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២២៨ ស្តីពី ការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈ នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះសពឯកឧត្តមស្វ៊ **សាញ់** ទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ២៣៥០

០៩-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២២៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ អ្នកស្រី **លឹម ហេង** សប្បុរសជននៅសហរដ្ឋអាមេរិក ២៣៥១

០៩-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៣០ ស្តីពី ការបញ្ចប់មុខតំណែងទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ០២ រូប តាមសំណើរបស់សាមីខ្លួន ២៣៥២

០៩-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៣១ ស្តីពី ការតែងតាំងជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ០២ រូប ២៣៥៣

០៩-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៣២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ឯកឧត្តម **ហុង ទូហាយ** ២៣៥៤

១០-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៣៣ ស្តីពី ការតែងតាំងសិស្សចៅក្រមជំនាន់ទី ៤ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ចំនួន ៦២ នាក់ឱ្យទៅបំពេញការងារជាចៅក្រមកម្មសិក្សានិង ព្រះរាជអាជ្ញារងកម្មសិក្សានៅតាមសាលាដំបូង និង អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ២៣៥៥

១០-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៣៤ ស្តីពី ការប្រែក្លាយមន្ទីរពេទ្យកាល់ម៉ែត ជាគ្រឹះស្ថានសាធារណៈសុខាភិបាល ២៣៥៩
១០-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៣៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោកជំទាវ **មិន ចណ្ឌីរ៉េណេត** ២៣៧៧
១០-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៣៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ និង នាយទាហាន ចំនួន ២២ រូប ២៣៧៨

## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ

១៤-៣-២០១១ -អនុក្រឹត្យលេខ ៤៣ អនក្រ.បក ស្តីពី ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ២៣៨០
១០-៣-២០១១ -អនុក្រឹត្យលេខ ២៦០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៣៨៣
១០-៣-២០១១ -អនុក្រឹត្យលេខ ២៦១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៣៨៥
១០-៣-២០១១ -អនុក្រឹត្យលេខ ២៦២ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ២៣៨៦
១០-៣-២០១១ -អនុក្រឹត្យលេខ ២៦៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៣៨៧
១០-៣-២០១១ -អនុក្រឹត្យលេខ ២៦៤ អនក្រ.តត ស្តីពី ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល អាណត្តិទី ៤ នៃរដ្ឋាករទឹកស្វយ័តភ្នំពេញ ២៣៨៩
១០-៣-២០១១ -អនុក្រឹត្យលេខ ២៦៥ អនក្រ.តត ស្តីពី ការលាលែងចេញពីក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ ២៣៩០
១១-៣-២០១១ -អនុក្រឹត្យលេខ ២៦៦ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ២៣៩២
១១-៣-២០១១ -អនុក្រឹត្យលេខ ២៦៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៣៩៣
១១-៣-២០១១ -អនុក្រឹត្យលេខ ២៦៨ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ២៣៩៤
១១-៣-២០១១ -អនុក្រឹត្យលេខ ២៦៩ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ២៣៩៦
១១-៣-២០១១ -អនុក្រឹត្យលេខ ២៧០ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ២៤១០
១១-៣-២០១១ -អនុក្រឹត្យលេខ ២៧១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២៤១៣
១៤-៣-២០១១ -អនុក្រឹត្យលេខ ២៧២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៤១៤
១៤-៣-២០១១ -អនុក្រឹត្យលេខ ២៧៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ២៤១៥
១៤-៣-២០១១ -អនុក្រឹត្យលេខ ២៧៤ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និង តែងតាំងមុខតំណែងនាយនគរបាលជាតិ ២៤១៧
១៤-៣-២០១១ -អនុក្រឹត្យលេខ ២៧៥ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ២៤១៩

# គ

១៥-៣-២០១១ -អនុក្រឹត្យលេខ ២៧៦ អនក្រ.បក ស្តីពី ការជូនមេដាយការងារ ២៤២០

## III_ការងារបណ្តាក្រសួង

### ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៤-០២-២០១១ -ប្រកាសលេខ ២១០ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន កុងស៊ី អ័រ & ឌី (ខេមបូឌា) បង្កើតរោងចក្រ ផលិតប្រេងជីវម៉ាស៊ូត (BIO-DIESEL) ពីគ្រាប់រុក្ខជាតិប្រេង ២៤៤៣

២៤-០២-២០១១ -ប្រកាសលេខ ២១១ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉េង ដា ហ្វូតវៀ អ៊ីនដាស់ស្ទ្រីល បង្កើតរោងចក្រ ផលិតស្បែកជើង ២៤៤៧

២៤-០២-២០១១ -ប្រកាសលេខ ២១២ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជូឌី ម៉ៅ (ខេមបូឌា) ហ្គាមេន អ៊ីនដឹ បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ២៤៥១

### ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៦-៥-២០១០ -លិខិតបញ្ជាក់លេខ ២១៣០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គុំធំរ ឌុយ (កាំបូដ)** ២៤៥៥

០៦-៥-២០១០ -លិខិតបញ្ជាក់លេខ ២១៣២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គីម អៀង ខូ អិលធីឌី** ២៤៥៧

០៦-៥-២០១០ -លិខិតបញ្ជាក់លេខ ២១៣៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេសធីប៊ី ត្រាវែល & ធួរ** ២៤៥៩

០៦-៥-២០១០ -លិខិតបញ្ជាក់លេខ ២១៣៨ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការសុំកែប្រែលក្ខន្តិកៈរបស់ **ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា** ២៤៦១

០៦-៥-២០១០ -លិខិតបញ្ជាក់លេខ ២១៤១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វីហ៊ើ អ៊ិនធើណេសិនណល ប៊ីលឌីង មេធៀរៀល (ខេមបូឌា) គ្រុប** ២៤៦៣

០៧-៥-២០១០ -លិខិតបញ្ជាក់លេខ ២១៤៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិនធើណេសិនណល ហ្គោល ម៉ាឃីត ខូ អិលធីឌី** ២៤៦៥

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២២៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៧៣ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **ខេង សំអាន** ពីអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ តាមសំណើរបស់សាមីខ្លួន។

**មាត្រា ២:** ត្រូវបានតែងតាំងសមាសភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដូចតទៅ÷

១. ឯកឧត្តម **ចាន់ តិរុណា** ជាអគ្គលេខាធិការ មានឋានៈស្មើអនុរដ្ឋលេខាធិការ

២. ឯកឧត្តម **ឆេស រុក្ខាផល** ជាអគ្គលេខាធិការរង មានឋានៈស្មើអគ្គនាយក។

**មាត្រា ៣:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល. ១១០៣.២៣០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០១១

លេខៈ ៤០៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០១១

អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល

ឃុន ជីនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២២៦

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម **លាង រ៉ូលាន** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២** : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល. ១១០៣.២៣១

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១១

លេខៈ ២១១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មីនា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២២៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **ស៊ាម សុខអួន** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១១០៣.២៣២

ថ្ងៃនៅព្រះបរមរាជវាំង . ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១១

លេខៈ ៤១៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

**ឃុន ជិនកេន**

នស/រកត/០៣១១/២២៩

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ជាកិត្តិយសបច្ឆាមរណៈ**

**នូវ**

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

**ចំពោះ**

**សពឯកឧត្តម ស៊ូ សាញ់**

ទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលមានគុណបំណាច់ក្នុងការបំរើជាតិមាតុភូមិ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣វល.១១០៣.២៣៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១១

លេខៈ ៥៤៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

**យុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/៧២៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

នូវ

## គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ចំពោះ

## អ្នកស្រី លឹម ហៀង

សប្បុរសជននៅសហរដ្ឋអាមេរិក មានគុណបំណាច់ និងស្នាដៃល្អដោយបានចូលរួមចំណែកក្នុងការកសាង សមិទ្ធផលនានាលើគ្រប់វិស័យ ស្ថិតនៅក្នុងស្រុកពារាំង ខេត្តព្រៃវែង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ១១០៣.៧៣៤

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១១

លេខ: ៧៣០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ជិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៣០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានកុមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានបញ្ចប់មុខតំណែងទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ០២រូប តាមសំណើរបស់សាមីខ្លួន ដូចមានរាយនាមខាងក្រោម ÷

១. ឯកឧត្តម **អាន ម៉ាឌី**

២. ឯកឧត្តម **លាង ឃុន**

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣... ០៣.២៣៥

លេខ: ២៤៦ ច.ល
ដើម្បីថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនភេន

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១១

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៣១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម÷

១. ឯកឧត្តម **ស៊ិន សារុន** មានឋានៈស្មើ រដ្ឋលេខាធិការ

២. ឯកឧត្តម **សៀង កែវឡាយ** មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៧. ១១០៣. ២៣៦

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១១

លេខ: ២២៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ ម៉ានិត

យ៉ង់ ជីនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៧២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

ចំពោះ

ឯកឧត្តម **ហុង ទូហាយ**

ដែលបានបរិច្ចាគធនធានចូលរួមចំណែកកសាងក្នុងវិស័យ
ព្រះពុទ្ធសាសនា នៅខេត្តសៀមរាប

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល. ១១០៣.២៣៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១១

លេខៈ ២៧៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មិនា ឆ្នាំ២០១១
អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៣៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហាមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកម/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានតែងតាំងសិស្សចៅក្រមជំនាន់ទី៤ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ចំនួន ៦២ នាក់ ឲ្យទៅបំរើការងារជាចៅក្រមកម្មសិក្សា និងព្រះរាជអាជ្ញារងកម្មសិក្សា នៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដូចខាងក្រោម:

**ក**-សាលាដំបូង-អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

១-លោក **ឆៃ ធីរៈ** ជាចៅក្រមកម្មសិក្សា

២-លោក **អ៊ី ម៉ាទរៈ** ជាចៅក្រមកម្មសិក្សា

៣-លោក **គុប ឈុនឡុង** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**ខ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកណ្តាល

១-លោក **អេង សុម៉ារិទ្ធ** ជាចៅក្រមកម្មសិក្សា

២-លោក **ឆេព មុនិន្ទ** ជាព្រះរាជអាជ្ញារងកម្មសិក្សា

៣-លោកស្រី **សុន សុខាលីដា** ជាព្រះរាជអាជ្ញារងកម្មសិក្សា

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៤-លោក **ឡាប ឡាយមុនី** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**គ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកំពង់ចាម

១-លោកស្រី **ហៃ ណៃរមាទ** ជាចៅក្រមកម្មសិក្សា

២-លោក **សម ម៉ុនផុន** ជាចៅក្រមកម្មសិក្សា

៣-លោក **វៀល សុភិន** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**ឃ**-សាលាដំបូងខេត្តបាត់ដំបង

១-លោក **យាប់ មេត្តា** ជាចៅក្រមកម្មសិក្សា

**ខ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តព្រៃវែង

១-លោក **ហេខ សុខជា** ជាចៅក្រមកម្មសិក្សា

២-លោក **ហាន សុខេមរិន** ជាចៅក្រមកម្មសិក្សា

៣-កញ្ញា **ឱុត រ៉ែនេណា** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**ច**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តសៀមរាប

១-លោក **ឈុន ច័ន្ទសីហា** ជាចៅក្រមកម្មសិក្សា

២-លោក **រ៉ែម សុភក្តិ** ជាចៅក្រមកម្មសិក្សា

៣-លោក **ជួន សុបញ្ញា** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**ឆ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តតាកែវ

១-លោក **ខ៊ាន់ សែន ទិសុទ្ធ** ជាចៅក្រមកម្មសិក្សា

២-លោក **ឌិន សុចិត្រា** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**ជ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ

១-លោក **យ៉ាន សុភាព** ជាចៅក្រមកម្មសិក្សា

២-លោក **ឌី មុនិន្ទ** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**ឈ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ

១-លោក **ម៉ម ច័ន្ទវណ្ណៈ** ជាចៅក្រមកម្មសិក្សា

២-លោក **លី ម៉េង** ជាចៅក្រមកម្មសិក្សា

៣-លោក **ផាន់ ភីរម្យ** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**ញ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកំពង់ធំ

១-លោក **ស៊ិត វណ្ណៈ** ជាចៅក្រមកម្មសិក្សា

២-លោក **គុជ គីមឡុង** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**ដ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកំពត

១-លោកស្រី **រស់ បុផ្ផាណា** ជាចៅក្រមកម្មសិក្សា

២-លោកស្រី **ខៀវ ផាន់ណា** ជាចៅក្រមកម្មសិក្សា

៣-លោក **ខាន់ សុផល** ជាព្រះរាជអាជ្ញារងកម្មសិក្សា

ឋ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តស្វាយរៀង

១-លោក **ភើត សាំង** ជាចៅក្រមកម្មសិក្សា

២-លោក **អ៊ិង រី** ជាព្រះរាជអាជ្ញារងកម្មសិក្សា

ឌ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង

១-លោក **ញូង ចន្ទី** ជាចៅក្រមកម្មសិក្សា

២-លោក **សុទ្ធ សំអោក** ជាចៅក្រមកម្មសិក្សា

៣-លោក **គីម ហុងសាន** ជាព្រះរាជអាជ្ញារងកម្មសិក្សា

ឍ-សាលាដំបូងខេត្តពោធិ៍សាត់

១-លោក **លី ចន្ថា** ជាចៅក្រមកម្មសិក្សា

២-លោក **ពេជ្រ ចិន្តា** ជាចៅក្រមកម្មសិក្សា

ណ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តក្រចេះ

១-លោកស្រី **គីម សុគន្ធា** ជាចៅក្រមកម្មសិក្សា

២-លោក **ហាក់ ហ៊ាន់** ជាព្រះរាជអាជ្ញារងកម្មសិក្សា

ត-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ

១-លោក **ញឹម ពិសាល** ជាចៅក្រមកម្មសិក្សា

២-កញ្ញា **លី សុជាណែត** ជាចៅក្រមកម្មសិក្សា

៣-លោក **ហួត វិចិត្រ** ជាព្រះរាជអាជ្ញារងកម្មសិក្សា

ថ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តព្រះវិហារ

១-លោក **សោ ពន្លក** ជាចៅក្រមកម្មសិក្សា

២-លោក **ស្រេង ឧទ្ធា** ជាព្រះរាជអាជ្ញារងកម្មសិក្សា

ទ-សាលាដំបូងខេត្តរតនគីរី

១-លោក **អេង ចំនាប់** ជាចៅក្រមកម្មសិក្សា

ធ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកោះកុង

១-កញ្ញា **ឈុន ដាវី** ជាចៅក្រមកម្មសិក្សា

២-លោកស្រី **សា កញ្ញារិទ្ធ** ជាព្រះរាជអាជ្ញារងកម្មសិក្សា

ន-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង

១-លោក **សាយ សារុន** ជាចៅក្រមកម្មសិក្សា

២-លោកស្រី **ស៊ុន យ៉ឹត** ជាព្រះរាជអាជ្ញារងកម្មសិក្សា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី

១-លោក **អែម សុខា** ជាចៅក្រមកម្មសិក្សា

២-លោក **សូ សុខិន្ធា** ជាព្រះរាជអាជ្ញារងកម្មសិក្សា

ឆ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តប៉ៃលិន

១-លោក **ឡុង វណ្ណា** ជាចៅក្រមកម្មសិក្សា

២-លោកស្រី **លី ម៉ារីណា** ជាចៅក្រមកម្មសិក្សា

៣-លោក **រ័ត្ន ស៊ីថា** ជាចៅក្រមកម្មសិក្សា

៤-លោក **នូ ដារ៉ា** ជាចៅក្រមកម្មសិក្សា

៥-លោក **សេង ផានិត** ជាព្រះរាជអាជ្ញារងកម្មសិក្សា

៦-លោក **សេង គីមឡាក់** ជាព្រះរាជអាជ្ញារងកម្មសិក្សា

ជ-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ

១-លោក **ផេង កុសល** ជាចៅក្រមកម្មសិក្សា

២-លោក **អាំង សុភា** ជាចៅក្រមកម្មសិក្សា

៣-លោក **គួន ចន្ថា** ជាចៅក្រមកម្មសិក្សា

៤-លោក **អ៊ិន ម៉ិនលី** ជាចៅក្រមកម្មសិក្សា

៥-លោក **សោ សុភ័ក្ត** ជាព្រះរាជអាជ្ញារងកម្មសិក្សា

៦-លោក **អ៊ុំ សុភក្តិ** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**មាត្រា២:** អស់លោក លោកស្រី ដែលមានឈ្មោះក្នុងមាត្រា១ ខាងលើនេះ ត្រូវបំពេញកម្មសិក្សារយៈពេល១២(ដប់ពីរ)ខែ ចាប់ពីថ្ងៃតែងតាំង ។

**មាត្រា៣:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៤:** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៥:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ករល. ១១០៣.២៣៨

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១១

លេខ: ៤៣៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០១១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនអេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៣៤

## ស្តីពី

## ការប្រែក្លាយមន្ទីរពេទ្យកាល់ម៉ែត ជាគ្រឹះស្ថានសាធារណៈសុខាភិបាល

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

# ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានប្រែក្លាយមន្ទីរពេទ្យកាល់ម៉ែតជាគ្រឹះស្ថានសាធារណៈសុខាភិបាល ដែលជានីតិបុគ្គលសាធារណៈស្ថិតនៅក្រោមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ ព្រមទាំងបទបញ្ជាផ្ទៃក្នុងមួយ ។

**មាត្រា ២.-**

២.១ មន្ទីរពេទ្យកាល់ម៉ែតជានីតិបុគ្គលសាធារណៈ និងមានស្វ័យភាពផ្នែកហិរញ្ញវត្ថុស្របតាមច្បាប់កំណត់ ។

២.២ មន្ទីរពេទ្យកាល់ម៉ែតមានបេសកកម្មបំរើសេវាសាធារណៈ និងផលប្រយោជន៍ទូទៅក្នុងវិស័យសុខាភិបាល ដែលមានភារកិច្ចជាអាទិ៍ :

១. ធានាពិនិត្យរោគវិនិច្ឆ័យ ព្យាបាល ថែរក្សាអ្នកជំងឺ ឬ អ្នករបួស មនុស្សពេញវ័យ កុមារ ទារក និងស្ត្រីមានគភ៌ ដែលត្រូវបញ្ជូន ឬ បានសុំមកព្យាបាលក្នុងមន្ទីរពេទ្យនេះ ព្រមទាំងផ្តល់ទីសំណាក់ជូនដល់ជនខាងលើតាមលទ្ធភាព និងសមត្ថភាពរបស់ខ្លួន ។

២. ផ្តល់ការថែរក្សាព្យាបាល ទាំងអ្នកជំងឺដែលមានសភាពស្រាលត្រូវការរយៈពេលខ្លី ទាំងអ្នកជំងឺធ្ងន់ដែលទាមទារចំណេះដឹងផ្នែកវេជ្ជសាស្ត្រ សល្យសាស្ត្រ គភ្ភបរិហារសាស្ត្រ និងទន្តវេទនសាស្ត្រ ។

៣. សហការក្នុងផ្នែកវេជ្ជសាស្ត្របង្ការការពារ ។

៤. ចូលរួមក្នុងចលនាសុខាភិបាលសាធារណៈ ។

៥. ចូលរួមក្នុងការសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលវិស័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទនសាស្ត្រ ។

៦. បង្កើត និងផ្តល់ការបណ្តុះបណ្តាលកម្រិតឧត្តមសិក្សា និងក្រោយឧត្តមសិក្សា ក្នុងវិស័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទនសាស្ត្រ ព្រមទាំងបណ្តុះបណ្តាលបុគ្គលិក ។



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៧. មន្ទីរពេទ្យកាល់ម៉ែតត្រូវចាត់វិធានការដើម្បីឆ្លើយតបនឹងការសង្គ្រោះអាសន្ន ឬ ការងសម្រួលឱ្យអ្នកជំងឺចូលមន្ទីរព្យាបាលដទៃទៀតតាមតម្រូវការវេជ្ជសាស្ត្រ ។

៨. ផ្តល់ឱ្យអ្នកជំងឺនូវការព្យាបាលរោគ ការបង្ការរោគ និងការសម្រាលរោគតាមតម្រូវការនៃស្ថានភាពជំងឺ ។

៩. ផ្តល់សេវាវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ ។

១០. ចាត់ចែងឱ្យបានល្អត្រឹមត្រូវនូវការព្យាបាលអាសន្នផ្នែកវេជ្ជសាស្ត្រសល្យសាស្ត្រ អាស្រ័យតាមមធ្យោបាយរបស់មន្ទីរពេទ្យ ។

១១. មិនត្រូវមានការរើសអើងក្នុងការព្យាបាលអ្នកជំងឺ ប៉ុន្តែអាចផ្តល់របបស្នាក់នៅកម្រិតខុសគ្នាអាស្រ័យតាមឆន្ទៈរបស់អ្នកជំងឺ ឬ គ្រួសារអ្នកជំងឺ ឬ អាស្រ័យតាមលទ្ធភាពចំណាយរបស់អ្នកជំងឺ អនុលោមតាមតម្លៃសេវាកម្មរបស់មន្ទីរពេទ្យកាល់ម៉ែត ។

២.៣ មន្ទីរពេទ្យកាល់ម៉ែតត្រូវចុះអនុសញ្ញាជាមួយសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ។

**មាត្រា ៣.-**

មន្ទីរពេទ្យកាល់ម៉ែតស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងសុខាភិបាល និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ២

## ការដឹកនាំ និងការគ្រប់គ្រង

### ផ្នែកទី ១

### ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាល

**មាត្រា ៤.-**

ក្រុមប្រឹក្សាភិបាលមន្ទីរពេទ្យកាល់ម៉ែត ដែលតទៅនេះហៅកាត់ថា ក្រុមប្រឹក្សាភិបាលជាអង្គការដឹកនាំខ្ពស់បំផុតរបស់មន្ទីរពេទ្យកាល់ម៉ែត ហើយបំពេញមុខងារប្រកបដោយស្វ័យភាពស្របតាមច្បាប់ជាធរមាន ។ ចំនួនសមាជិកនៃក្រុមប្រឹក្សាភិបាលមិនត្រូវលើសពី ៧ (ប្រាំពីរ) រូបឡើយ ។

**មាត្រា ៥.-**

មន្ទីរពេទ្យកាល់ម៉ែតត្រូវដឹកនាំដោយប្រធានមួយរូបដែលជាអគ្គនាយក ដែលបំពេញមុខងារក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ៦.-**

អគ្គនាយកត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងនាយករដ្ឋមន្ត្រី ។ សមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬ អាជ្ញាធរដែលសមាជិកនោះជាតំណាង ។

**មាត្រា ៧.-**

៧.១ ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- អគ្គនាយក មួយរូប | ប្រធាន |
| ២- តំណាងក្រសួងសុខាភិបាល មួយរូប | សមាជិក |
| ៣- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយរូប | សមាជិក |
| ៤- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី មួយរូប | សមាជិក |
| ៥- តំណាងសាលារាជធានី មួយរូប | សមាជិក |
| ៦- សាកលវិទ្យាធិការសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល មួយរូប | សមាជិកស្វ័យប្រវត្តិ |
| ៧- តំណាងមន្ត្រីរាជការ បុគ្គលិក មួយរូប | សមាជិកស្វ័យប្រវត្តិ |

៧.២ សមាជិកក្រុមប្រឹក្សាភិបាល ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ (បី) ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់គ្រប់ពេលវេលាដោយអនុក្រឹត្យតាមសំណើនៃក្រសួង ឬ អាជ្ញាធរដែលខ្លួនតំណាងឱ្យ ។

៧.៣ បទបញ្ជាផ្ទៃក្នុងនៃមន្ទីរពេទ្យអាចអនុញ្ញាតឱ្យឥស្សរជនខ្លះនៅក្នុង ឬ ក្រៅស្ថាប័នដែលមានបទពិសោធន៍ផ្នែកសុខាភិបាលចូលរួមក្នុងអង្គប្រជុំនៃក្រុមប្រឹក្សាភិបាល និងមានសិទ្ធិផ្តល់មតិតែពុំមានសិទ្ធិចូលរួមបោះឆ្នោតឡើយ ។

**មាត្រា ៨.-**

ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទីកោះប្រជុំ និងកំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងធានារាល់របៀបរៀបរយនៃកិច្ចប្រជុំឱ្យបានប្រសើរ ។

**មាត្រា ៩.-**

ក្រុមប្រឹក្សាភិបាលមានបេសកកម្មដឹកនាំ តម្រង់ទិសដៅ និងធ្វើការត្រួតពិនិត្យមន្ទីរពេទ្យនេះ ដោយជៀសវាងមិនឱ្យប៉ះពាល់ដល់សិទ្ធិអាណាព្យាបាលទូទៅរបស់រដ្ឋ ។ ក្នុងករណីនេះ ក្រុមប្រឹក្សាភិបាល អាចសម្រេចលើ :

១. អង្គការលេខនៃមន្ទីរពេទ្យ

២. គម្រោងអភិវឌ្ឍនៃមន្ទីរពេទ្យ

៣. កម្មវិធីសកម្មភាពសម្រាប់អនាគត

៤. កម្មវិធីវិនិយោគស្តីពីសំណង់ធំៗ និងបរិក្ខារសំខាន់ៗផ្សេងៗ

៥. ថវិកាចំបង និងថវិកាបន្ថែម

៦. ការកំណត់តម្លៃសេវាកម្មផ្តល់ដោយមន្ទីរពេទ្យ

៧. របាយការណ៍គ្រប់គ្រង និងរបាយការណ៍គណនេយ្យប្រចាំឆ្នាំ

៨. ការបែងចែកប្រាក់ចំណេញ

៩. ការបង្កើតថ្មី ការលុប ការប្តូរវេចនាសម្ព័ន្ធ ក្នុងវិស័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទនសាស្ត្រ និងការបណ្តុះបណ្តាល

១០. តារាងតំណែងអចិន្ត្រៃយ៍ និងគម្រោងហ្វឹកហ្វឺនបុគ្គលិក

១១. ការតែងតាំងប្រធានផ្នែកនៃមន្ទីរពេទ្យ

១២. គោលនយោបាយបែងចែកផលប្រយោជន៍ដល់បុគ្គលិក

១៣. ការទទួលវិភាគទានទាំងឡាយ

១៤. ការលក់ ទិញ ដូរ និងជួលអចលនទ្រព្យគ្រប់ប្រភេទស្របតាមច្បាប់កំណត់

១៥. ការខ្ចីបុលហិរញ្ញប្បទានជាឥណទាន ទុនបន្ថែមថ្មី ឬ ការចូលរួមចំណែកភាគទុនផ្សេងៗស្របតាមច្បាប់កំណត់

១៦. បទបញ្ជាផ្ទៃក្នុងនៃមន្ទីរពេទ្យ

១៧. ការអនុញ្ញាតចំពោះកិច្ចសន្យា ឬ អនុសញ្ញា ដែលទាមទារការសម្រេចរួមនៃក្រុមប្រឹក្សាភិបាល ក្នុងករណីចាំបាច់ ។

**មាត្រា ១០.-**

១០.១ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល កំណត់លាភការ និងប្រាក់បំណាច់សម្រាប់សមាជិកក្រុមប្រឹក្សាភិបាល ។

១០.២ លាភការ ឬ ប្រាក់បំណាច់ខាងលើអាចត្រូវបញ្ឈប់ចំពោះសមាជិកណាម្នាក់នៃក្រុមប្រឹក្សាភិបាល ដែលមិនបំពេញភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវដោយក្រសួង ឬ អាជ្ញាធរជាអ្នកតែងតាំងសមាជិករូបនោះ ។ ភារកិច្ចនេះមានជាអាទិ៍ :

១. ការមកប្រជុំទៀងទាត់

២. ការគោរពបទប្បញ្ញត្តិច្បាប់ទាំងឡាយនៃមន្ទីរពេទ្យ

៣. ការការពារបន្ទាត់នយោបាយ និងផលប្រយោជន៍អាជ្ញាធរ ឬ ក្រសួងដែលខ្លួនតំណាងឲ្យ

៤. ការជូនព័ត៌មាន និងសេចក្តីរាយការណ៍ដល់អាជ្ញាធរ និងក្រសួងដែលខ្លួននៅក្រោមឱវាទ ។

**មាត្រា ១១.-**

១១.១ ក្រុមប្រឹក្សាភិបាលធ្វើការប្រជុំគ្រប់វេលា អាស្រ័យលើអត្ថប្រយោជន៍នៃមន្ទីរពេទ្យតាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើរបស់សមាជិក ៣ (បី) នាក់ ឬ អគ្គនាយក ។ យ៉ាងហោចការប្រជុំនេះត្រូវមានមួយលើកក្នុងមួយឆមាស ។ ក្រុមប្រឹក្សាភិបាលពិភាក្សាលើបញ្ហាទាំងឡាយដែលចែងក្នុងរបៀបវារៈ ។ របៀបវារៈ ព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និងក្រសួងពាក់ព័ន្ធផ្សេងទៀតដែលមានចែងក្នុងព្រះរាជក្រឹត្យនេះយ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃប្រជុំ ។

១១.២ កិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះត្រាតែសមាជិកវត្តមានមានចំនួន ៤ (បួន) នាក់ យ៉ាងតិចនៃបណ្តាសមាជិកទាំងអស់ ។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឲ្យមកប្រជុំជំនួសខ្លួនបានឡើយ ។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួនទេ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀតយ៉ាងយូរ ៨ (ប្រាំបី) ថ្ងៃ ក្រោយថ្ងៃប្រជុំលើកមុន ហើយសម័យប្រជុំ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

លើកក្រោយនេះមិនទាមទារកូរ៉ុមទេ ។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន ។ ប្រសិនបើការបែកសំឡេងស្មើគ្នាពុំអាចដាច់ស្រេចបាននោះ សំឡេងប្រធានក្រុមប្រឹក្សាភិបាលមានអាទិភាពលើសំឡេងសមាជិកធម្មតា ។

១១.៣ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងបញ្ជីពិសេសមួយ តម្កល់ទុកនៅទីចាត់ការរបស់មន្ទីរពេទ្យ និងត្រូវបានចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល ។ លេខាធិការដ្ឋាននៃអង្គប្រជុំក្រុមប្រឹក្សាភិបាលត្រូវធានាដោយអគ្គនាយក ។ កំណត់ហេតុនេះត្រូវបង្ហាញនូវអត្ថន័យនៃការពិភាក្សាឱ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនគ្រប់សមាជិក និងក្រសួងពាក់ព័ន្ធផ្សេងទៀតយ៉ាងយូរ ១០ (ដប់) ថ្ងៃ ក្រោយពេលប្រជុំ ។ ក្នុងករណីមានសមាជិកណាម្នាក់ធ្វើការកត់សំគាល់លើចំណុចអ្វីមួយនាសម័យប្រជុំបន្ទាប់ ការកត់សំគាល់នេះត្រូវកត់ត្រាចូលឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុនៃសម័យប្រជុំលើកក្រោយ ។

## ផ្នែកទី ២

## អង្គការប្រតិបត្តិនៃមន្ទីរពេទ្យ

**មាត្រា ១២.-**

មន្ទីរពេទ្យកាល់ម៉ែតត្រូវបានដឹកនាំដោយអគ្គនាយក ដែលតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង នាយករដ្ឋមន្ត្រី ។ មុននឹងចូលទទួលតំណែងរបស់ខ្លួន អគ្គនាយកត្រូវបំពេញកម្មសិក្សាយ៉ាងតិច ៣ (បី) ខែ នៅក្នុងមន្ទីរពេទ្យស្វយ័តណាមួយ និងទទួលការហ្វឹកហ្វឺនបន្ថែមខាងផ្នែកគ្រប់គ្រង ។ អគ្គនាយកអាចត្រូវបញ្ឈប់គ្រប់ពេលវេលាដោយព្រះរាជក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង នាយករដ្ឋមន្ត្រី ។

**មាត្រា ១៣.-**

អគ្គនាយករបស់មន្ទីរពេទ្យកាល់ម៉ែតពុំអាចទទួលអាណត្តិជាអ្នកតំណាងរាស្ត្រ ឬ បំពេញមុខងារក្នុងសមាជិករាជរដ្ឋាភិបាលបានឡើយ ។

**មាត្រា ១៤.-**

១៤.១ អគ្គនាយកជាតំណាងមន្ទីរពេទ្យចំពោះមុខគតិយជនទាំងឡាយ ។

១៤.២ អគ្គនាយកមានភារកិច្ច :

១. រៀបចំការប្រជុំក្រុមប្រឹក្សាភិបាល

២. ទទួលអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងការដាក់ឱ្យដំណើរការនូវនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាល

៣. រៀបចំថវិកាប្រចាំឆ្នាំរបស់មន្ទីរពេទ្យកាល់ម៉ែត ហើយដាក់ជូនក្រុមប្រឹក្សាភិបាល

៤. រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំ និងគណនេយ្យហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយដាក់ជូនក្រុមប្រឹក្សាភិបាល

៥. បញ្ជាក់អំពីមុខការសម្រាប់ផ្នែកជំនាញនៃមន្ទីរពេទ្យតាមតម្រូវការ

៦. បំពេញតំណែងក្នុងមន្ទីរពេទ្យក្នុងកម្រិតចំនួនក្របខ័ណ្ឌបុគ្គលិកដែលកំណត់ដោយក្រុមប្រឹក្សាភិបាល និងដោយគោរពតាមវិធានស្តីពីការគ្រប់គ្រងបុគ្គលិក

៧. អនុវត្តគ្រប់គ្រងតាមឋានានុក្រមចំពោះបុគ្គលិកទាំងមូល ទោះមានឋានៈជាអ្វីក៏ដោយ

៨. ចុះហត្ថលេខាលើអនុសញ្ញាស្របតាមការប្រគល់សិទ្ធិពីក្រុមប្រឹក្សាភិបាល ស្របតាមបទបញ្ជាផ្ទៃក្នុង និងស្របតាមបទប្បញ្ញត្តិដែលពាក់ព័ន្ធករណីនេះ

៩. គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈស្របតាមច្បាប់ជាធរមាន

១០. ចុះអនុសញ្ញាជាមួយដៃគូ ឬ អង្គការដទៃទៀត

១១. សរុបគឺបំពេញមុខងារដឹកនាំ និងគ្រប់គ្រងដល់ដំណើរការជាប្រចាំរបស់មន្ទីរពេទ្យកាល់ម៉ែត ។

១៤.៣ អគ្គនាយកត្រូវស្នើទៅរដ្ឋមន្ត្រីក្រសួងសុខាភិបាលសុំតែងតាំងអគ្គនាយករង ១ (មួយ) រូប ឬ ច្រើនរូប ដើម្បីជួយការងាររបស់ខ្លួន ។

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL ★

## ផ្នែកទី ៣
## បុគ្គលិកនៃមន្ទីរពេទ្យ

**មាត្រា ១៥.-**

១៥.១ បុគ្គលិកអចិន្ត្រៃយ៍របស់មន្ទីរពេទ្យកាល់ម៉ែតរួមមាន មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈដែលមានស្រាប់ ឬ មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈដែលរដ្ឋមន្ត្រីក្រសួងសុខាភិបាលផ្ទេរមកឱ្យធ្វើការនៅមន្ទីរពេទ្យកាល់ម៉ែត ដោយមានការយល់ព្រមពីអគ្គនាយកតាមការប្រឡងជ្រើសរើស ។ មន្ត្រីទាំងឡាយនេះត្រូវបានរក្សាទុកក្របខ័ណ្ឌប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន ។

១៥.២ ក្រៅពីនេះមន្ទីរពេទ្យអាចជ្រើសរើសភ្នាក់ងារ អ្នកជំនួយ និងបុគ្គលិកអណ្តែតដោយកិច្ចសន្យា ។ បុគ្គលិកទាំងនេះពុំអាចទទួលលក្ខណសម្បត្តិជាភ្នាក់ងាររាជការក្របខ័ណ្ឌមុខងារសាធារណៈឡើយ ។ ការគ្រប់គ្រងបុគ្គលិកទាំងអស់នេះស្ថិតនៅក្រោមបទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

១៥.៣ ប្រាក់កម្រៃលើកទឹកចិត្តត្រូវផ្តល់ឱ្យបុគ្គលិកគ្រប់រូប ។ បែបបទសម្រាប់ទូទាត់ប្រាក់កម្រៃនេះត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៦.-**

បុគ្គលិកនៃមន្ទីរពេទ្យកាល់ម៉ែតត្រូវទទួលធ្វើការងារពិសេសទាំងឡាយទាក់ទងនឹងតម្រូវការរបស់មន្ទីរពេទ្យក្នុងឋានៈជាអ្នកផ្តល់សេវាសាធារណៈ ។

## ផ្នែកទី ៤
## ទ្រព្យសម្បត្តិរបស់មន្ទីរពេទ្យ

**មាត្រា ១៧.-**

១៧.១ មន្ទីរពេទ្យកាល់ម៉ែតទទួលដើមទុនដំបូងពីរដ្ឋជាដីធ្លី និងអចលនវត្ថុដែលមានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធតាមបញ្ជីសារពើភណ្ឌចុងក្រោយដែលមានផ្ទៃដី ៣៧ ១៣១ (សាមសិបប្រាំពីរ



ROYAUME DU CAMBODGE · LE MINISTRE DU PALAIS

៣ាន មួយរយសាមសិបមួយ) ម៉ែត្រក្រឡា ក្នុងនោះមានអាសយដ្ឋានលេខ ៨ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

១៧.២ មន្ទីរពេទ្យមានសិទ្ធិទិញដូរអចលនទ្រព្យ និងចលនទ្រព្យទាំងឡាយដែលចាំបាច់សម្រាប់ដំណើរការរបស់ខ្លួន លើកលែងដី និងអគារ ។

១៧.៣ មន្ទីរពេទ្យអាចមានទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលបានមកពីការទិញនិងគ្រប់គ្រង ស្របតាមបទប្បញ្ញត្តិរបស់មន្ទីរពេទ្យ ។

## ជំពូកទី ៥

## ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យនៃមន្ទីរពេទ្យ

**មាត្រា ១៨.-**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យនៃមន្ទីរពេទ្យកាលម៉ែតត្រូវប្រព្រឹត្តទៅស្របតាមគោលការណ៍នៃគណនេយ្យសាធារណៈជាធរមាន ។

**មាត្រា ១៩.-**

អគ្គនាយកជាអាណាប័កដើមខ្សែក្នុងការចំណាយថវិកានៃមន្ទីរពេទ្យ ។

១៩.១ ក្នុងន័យនេះអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់មន្ទីរពេទ្យ អគ្គនាយកត្រូវ:

១- ចាត់ចែងត្រួតពិនិត្យប្រាក់ និងទូទាត់ចំណូល

២- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ

១៩.២ ក្នុងការចំណាយរបស់មន្ទីរពេទ្យ អាណាប័កដើមខ្សែអាចផ្តល់សិទ្ធិប្រទានឲ្យទៅអាណាប័កផ្ទេរសិទ្ធិ ។

**មាត្រា ២០.-**

២០.១ ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យត្រូវប្រព្រឹត្តស្របតាមបទបញ្ជាផ្ទៃក្នុងមន្ទីរពេទ្យ ក្រោមការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ភ្នាក់ងារគណនេយ្យដែលមានលក្ខណសម្បត្តិជាគណនេយ្យករសាធារណៈ ។ ភ្នាក់ងារនេះត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង



សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលស្នើសុំដោយអគ្គនាយកតាមរយៈក្រសួងសុខាភិបាល ហើយធ្វើសម្បថមុនទីនឹងទទួលតំណែង ។ ភ្នាក់ងារគណនេយ្យនេះមានសិទ្ធិចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាល អាចផ្តល់មតិ តែឥតមានសំឡេងឆ្នោតឡើយ ។

២០.២ ភ្នាក់ងារគណនេយ្យនេះមានភារកិច្ចដូចតទៅ :

១. ប្រមូលចំណូល
២. ទូទាត់ចំណាយ
៣. ថែរក្សាទ្រព្យសម្បត្តិ និងគ្រប់គ្រងមូលនិធិ ធនធានហិរញ្ញវត្ថុមន្ទីរពេទ្យ
៤. ថែរក្សាលិខិតយុត្តិការ និងកាន់កាប់បញ្ជីការគណនេយ្យ ។

២០.៣ ភ្នាក់ងារគណនេយ្យអាចផ្តល់សិទ្ធិប្រទានទៅឱ្យតំណាងរបស់ខ្លួន ដោយមានការឯកភាពពីអគ្គនាយក ។

**មាត្រា ២១.-**

២១.១ ធនធានរបស់មន្ទីរពេទ្យកាល់ម៉ែតមានជាអាទិ៍ :

១. ធនធានដំបូងដែលរដ្ឋឧបត្ថម្ភ
២. វិភាគទានដែលមានបំរុងក្នុងថវិការដ្ឋ សម្រាប់ប្រាក់បៀវត្ស និងប្រាក់កំរៃផ្សេងៗ របស់មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ការចំណាយថ្លៃទឹក ថ្លៃភ្លើង ប្រាក់ឧបត្ថម្ភធ្នូបសម្រាលកូន សោហ៊ុយចំណាយសម្រាប់ការពិនិត្យ ព្យាបាលអ្នកជំងឺក្រីក្រ ឬ អ្នកជំងឺដទៃទៀត និងសោហ៊ុយដំណើរការចាំបាច់សម្រាប់ការព្យាបាលភាពអាសន្ន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល ។
៣. ប្រាក់ឧបត្ថម្ភដែលបានមកពីវិភាគទាន ឬ អំណោយពីកេ្តីមរតកឯកជន
៤. ប្រាក់ខ្ចីពីគេស្របតាមបទប្បញ្ញត្តិជាធរមាន និងប្រាក់ដែលរដ្ឋខ្ចីឱ្យ
៥. ហិរញ្ញប្បទានសហប្រតិបត្តិការផ្សេងៗពីដៃគូអភិវឌ្ឍនានា
៦. ទុនបានមកពីការបង្កើតភាគហ៊ុន ឬ ការចូលរួមចំណែកភាគទុនពីអតិថិជនជាសមាជិក ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៧. ចំណូលបានពីសេវាកម្មនៃមន្ទីរពេទ្យស្របតាមការកំណត់របស់ក្រុមប្រឹក្សាភិបាល

៨. ប្រាក់កំរៃបានមកពីការលក់ ឬ ការជួលចលនវត្ថុ ឬ អចលនវត្ថុរបស់មន្ទីរពេទ្យ ។

២១.២ ចំណូល និងចំណាយចរន្ត ឬ ចំណូល និងចំណាយមូលធនត្រូវមានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់មន្ទីរពេទ្យ ។

២១.៣ ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យសម្រេច ។ ក្រុមប្រឹក្សាភិបាលត្រូវអនុម័តគម្រោងថវិកានេះឲ្យបានមុនថ្ងៃទី ៣១ ខែ កក្កដា រៀងរាល់ឆ្នាំ ។

២១.៤ ថវិកាដែលបានមកពីការរំលស់សំណង់ និងបរិក្ខារទាំងឡាយ មន្ទីរពេទ្យកាល់ម៉ែតត្រូវរក្សាទុកសម្រាប់ការទិញថ្មី និងជួសជុលធំ ។

២១.៥ កាតព្វកិច្ចថ្មីណាមួយផ្នែកសុខាភិបាលសាធារណៈដែលរដ្ឋតម្រូវឱ្យមន្ទីរពេទ្យទទួលបន្ទុក ត្រូវដោះស្រាយដោយអនុសញ្ញារវាងមន្ទីរពេទ្យ និងក្រសួងសុខាភិបាល ឬ ក្រសួង និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីបញ្ជាក់ល័ក្ខខ័ណ្ឌសោហ៊ុយក្នុងការអនុវត្តកាតព្វកិច្ចនេះ ។

**មាត្រា ២២.-**

២២.១ ការងារគណនេយ្យរបស់មន្ទីរពេទ្យកាល់ម៉ែតរួមមាន :

១. គណនេយ្យទូទៅដែលត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគដែលបែងអំពីប្រតិបត្តិការផ្នែកថវិការតនាគារ និងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន

២. គណនេយ្យអសង្ហារឹម រូបធាតុ និងគណនេយ្យតម្លៃ

៣. គណនេយ្យវិភាគតាមតម្រូវការ

គណនេយ្យរបស់មន្ទីរពេទ្យកាល់ម៉ែតត្រូវ :

- ស្របតាមវិធានដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គោរពប្លង់គណនេយ្យរបស់មន្ទីរពេទ្យកាល់ម៉ែតដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។

ប្លង់គណនេយ្យនេះត្រូវយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២២.២ របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់មន្ទីរពេទ្យត្រូវរៀបចំដោយភ្នាក់ងារគណនេយ្យដែលភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣ (បី) ខែ ក្រោយពេលបិទការិយបរិច្ឆេទគណនេយ្យ ។

**មាត្រា ២៣.-**

មន្ទីរពេទ្យកាលម៉ែតត្រូវអនុញ្ញាតឱ្យមានគណនីនៅធនាគារណាមួយ ឬច្រើន ទៅតាមការចាំបាច់របស់ខ្លួន ។

**មាត្រា ២៤.-**

ការប្រើប្រាស់ប្រាក់ចំណេញនៃមន្ទីរពេទ្យកាលម៉ែតត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាល ។ ប្រាក់ចំណេញទាំងនេះអាចដាក់តម្កល់យកការប្រាក់នៅធនាគារបាន ។

## ផ្នែកទី ៦

## របបសារពើពន្ធ និងពន្ធគយ

**មាត្រា ២៥.-**

លើកលែងតែមានបដិប្បញ្ញត្តិដែលមានចែងដោយច្បាប់ មន្ទីរពេទ្យកាលម៉ែតត្រូវស្ថិតនៅក្រោមនីតិរបបចំពោះរបបសារពើពន្ធដូចគ្នានឹងអង្គភាពនានារបស់រដ្ឋ ។

## ផ្នែកទី ៧

## កិច្ចសន្យានៃមន្ទីរពេទ្យ

**មាត្រា ២៦.-**

ការចុះ ការអនុវត្ត និងការពិនិត្យកិច្ចសន្យារបស់មន្ទីរពេទ្យកាលម៉ែតត្រូវគោរពតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

## ជំពូកទី ៣

## អាណាព្យាបាលលើមន្ទីរពេទ្យ

**មាត្រា ២៧.-**

២៧.១ មន្ទីរពេទ្យកាល់ម៉ែតត្រូវផ្ញើជូន គណៈរដ្ឋមន្ត្រី ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលមានចែងនៅក្នុងមាត្រា ៣៣ ខាងក្រោមនេះ នូវឯកសារដូចតទៅ :

- កំណត់ហេតុកិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល
- គម្រោងអភិវឌ្ឍរបស់មន្ទីរពេទ្យ
- ថវិកាប្រចាំឆ្នាំ
- របាយការណ៍គ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ

២៧.២ ឯកសារទាំងនេះត្រូវផ្ញើជូនយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយថ្ងៃប្រជុំក្រុមប្រឹក្សាភិបាល ។

## ផ្នែកទី ១

## អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៨.-**

២៨.១ គម្រោងអភិវឌ្ឍ ឬ ថវិកាប្រចាំឆ្នាំនៃមន្ទីរពេទ្យត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយអគ្គនាយក ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយការអនុម័តនៃក្រុមប្រឹក្សាភិបាល ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវផ្តល់មតិទៅក្រសួងសុខាភិបាលក្នុងរយៈពេលយ៉ាងយូរ ១ (មួយ) ខែ ចាប់ពីថ្ងៃទទួលឯកសារខាងលើនេះ ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវផ្តល់ការយល់ព្រមក្នុងរយៈពេល ២ (ពីរ) ខែ ចាប់ពីថ្ងៃទទួលឯកសារទាំងនេះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២៨.២ លិខិតផ្តល់ឯកភាពចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬ តំណាងត្រូវផ្ញើទៅអគ្គនាយក និងត្រូវចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អគ្គនាយកត្រូវជូនព័ត៌មាននេះឱ្យក្រុមប្រឹក្សាភិបាលបានជ្រាបយ៉ាងឆាប់បំផុត ។

ក្នុងករណីដែល រដ្ឋមន្ត្រីក្រសួងសុខាភិបាលមិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើ គម្រោងអភិវឌ្ឍ ឬ ថវិកាប្រចាំឆ្នាំត្រូវចាត់ទុកថាបានទទួលការឯកភាពពីរដ្ឋមន្ត្រីនេះហើយ ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសុខាភិបាលមានយោបល់ជំទាស់ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័ស ដើម្បីរកមធ្យោបាយដោះស្រាយបញ្ហានេះ ។

គម្រោងអភិវឌ្ឍនៃមន្ទីរពេទ្យមិនអាចអនុវត្តបាន បើសិននៅមានការមិនចុះសម្រុងនៃរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

ថវិកាចំណាយប្រក្រតីត្រូវអនុវត្តផ្អែកលើ "ប្រព័ន្ធបែងចែកជា ១២ (ដប់ពីរ) ខែ" បើសិនជារដ្ឋមន្ត្រីក្រសួងសុខាភិបាលនៅតែមានមតិមិនចុះសម្រុងបន្តទៀត ។

**មាត្រា ២៩.-**

២៩.១ រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចមានយោបល់ជំទាស់លើឯកសារដែលបានទទួល ដូចមានចែងក្នុងមាត្រា ២៧ ខាងលើនេះ ហើយមានរយៈពេល ១ (មួយ) ខែ ដើម្បីលើកមតិជំទាស់លើឯកសារទាំងនេះ ។

២៩.២ អគ្គនាយកត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាលនូវយោបល់ជំទាស់របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ក្នុងសម័យប្រជុំយ៉ាងឆាប់មួយ ។ ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សារកមធ្យោបាយដើម្បីដោះស្រាយយោបល់ជំទាស់នេះឱ្យបានឆាប់រហ័ស ។ បើសិនជាក្រុមប្រឹក្សាភិបាលមិនស្របនឹងយោបល់ជំទាស់នេះ ក្រុមប្រឹក្សាភិបាលត្រូវពន្យល់ដោយលាយលក្ខណ៍អក្សរនូវជំហររបស់ខ្លួនជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ៣០.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានសិទ្ធិសុំឱ្យមានការត្រួតពិនិត្យមន្ទីរពេទ្យតាមតម្រូវការ និងស្របតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងច្បាប់ពាក់ព័ន្ធនឹងការត្រួតពិនិត្យនេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ផ្នែកទី ២

## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ៣១.-**

៣១.១ របាយការណ៍គ្រប់គ្រង និងថវិកាប្រចាំឆ្នាំត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយអគ្គនាយក ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយការអនុម័តនៃក្រុមប្រឹក្សាភិបាល ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវផ្តល់មតិទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលយ៉ាងយូរ ១ (មួយ) ខែ ចាប់ពីថ្ងៃទទួលឯកសារខាងលើនេះ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវផ្តល់ការយល់ព្រមក្នុងរយៈពេល ២ (ពីរ) ខែ ចាប់ពីថ្ងៃដែលទទួលឯកសារខាងលើនេះ ។

៣១.២ លិខិតផ្តល់ឯកភាពចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ តំណាង ត្រូវផ្ញើទៅអគ្គនាយកដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ អគ្គនាយកត្រូវជូនព័ត៌មាននេះឲ្យក្រុមប្រឹក្សាភិបាលបានជ្រាបយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើ របាយការណ៍គ្រប់គ្រង និងថវិកាប្រចាំឆ្នាំត្រូវចាត់ទុកថាបានទទួលការឯកភាពពីរដ្ឋមន្ត្រីនេះហើយ ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានយោបល់ជំទាស់ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឲ្យបានឆាប់រហ័ស ដើម្បីរកមធ្យោបាយដោះស្រាយបញ្ហានេះ ។

របាយការណ៍គ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំទាំងឡាយត្រូវចាត់ទុកថាគ្មានការយល់ព្រម បើសិនការមិនចុះសម្រុងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនទាន់ត្រូវដោះស្រាយបាន ។

**មាត្រា ៣២.-**

សារលិខិតដូចខាងក្រោមនេះរបស់ក្រុមប្រឹក្សាភិបាល ឬ អគ្គនាយកត្រូវដាក់សុំការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្លងតាមយោបល់របស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ការលក់ចលនទ្រព្យ
- ការលុបចោលនូវគណនេយ្យដែលមានទឹកប្រាក់លើសកម្រិតមួយ មានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការសម្រេចខ្ទីបុល ឬ កិច្ចព្រមព្រៀងធានា ឬ លិខិតស្នាមដែលមានកម្មវត្ថុប្រហាក់ប្រហែលគ្នានេះ ។

**មាត្រា ៣៣.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំមន្ទីរពេទ្យកាល់ម៉ែត ។ មន្ត្រីនេះមានភារកិច្ចត្រួតពិនិត្យមុនទង្វើ និងក្រោយទង្វើ ស្របតាមបញ្ញត្តិទាំងឡាយស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុដែលមានជាធរមាន ។

**មាត្រា ៣៤.-**

៣៤.១ ការគ្រប់គ្រងដោយអាណាប័កដើមខែនៃមន្ទីរពេទ្យស្ថិតនៅក្រោមការត្រួតពិនិត្យនៃអគ្គាធិការកិច្ចហិរញ្ញវត្ថុ ។

៣៤.២ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសិទ្ធិសុំឱ្យមានការត្រួតពិនិត្យមន្ទីរពេទ្យកាល់ម៉ែតតាមតម្រូវការតាមការចាំបាច់ ស្របតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធនឹងកិច្ចការត្រួតពិនិត្យនេះ ។

## ជំពូកទី ៤

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៥.-**

នៅពេលណាដែលពិនិត្យឃើញថា មន្ទីរពេទ្យកាល់ម៉ែតមានអតិរេកសមស្រប និងស្ថិរភាព ក្រសួងអាណាព្យាបាលទាំងពីរអាចពិនិត្យកាត់បន្ថយវិភាគទានរបស់រដ្ឋជាបណ្តើរៗ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦.-**

៣៦.១ ព្រះរាជក្រឹត្យលេខនស/រកត/១២៩៦/៩៤ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៦ និងបទប្បញ្ញត្តិទាំងឡាយណាផ្ទុយពីព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

៣៦.២ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវ ព្រះរាជក្រឹត្យនេះ ។

៣៦.៣ ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល.១១០៣.២៣៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខ: ៤.៧១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មីនា ឆ្នាំ២០១១

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

១៨/១៨

ឃុន ជិនកេន

18/18

នស/រកត/០៣១១/២៣៥

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

**ចំពោះ**

**លោកជំទាវ មិន ចណ្ឌីណែត**

មានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ លើវិស័យធម្មការ និងសាសនា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រណ. ១១០៣.២៤០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១១

លេខៈ ៤៣១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៣៦

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោធិភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

**ចំពោះ**

មន្ត្រីរាជការ និងនាយទាហាន ចំនួន២២រូប ដែលបានជួយឧបត្ថម្ភ ថវិកា សំភារៈ ដល់ការកសាង និង អភិវឌ្ឍន៍គ្រប់វិស័យ ក្នុងខេត្តព្រះវិហារ

នូវ

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

ឯកឧត្តម **ឈិន ច័ន្ទពណ៌**

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

ឯកឧត្តម **អ៊ុំ បុត្រ**

**គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១ ឯកឧត្តម **កែវ ពៅ**
២ ឯកឧត្តម **អ៊ុច វ៉ាន់ថា**
៣ ឯកឧត្តម **អ៊ុក កោសា**

**ឃ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

១ ឯកឧត្តម **ចាប វ៉ាន់នី**
២ ឯកឧត្តម **សំរិទ្ធ ហ៊ុន**
៣ ឯកឧត្តម **យឿង សុខុន**
៤ ឯកឧត្តម **ហ៊ុំ រដ្ឋា**
៥ ឯកឧត្តម **ខឹម ជាសាយឿន**
៦ ឯកឧត្តម **អួន លន**
៧ ឯកឧត្តម **សេង សារី**
៨ លោក **ម៉ន សាម៉ុន**

| | | | |
|---|---|---|---|
| ៩ | ឯកឧត្តម | រស់ | ទៀត |
| ១០ | លោក | ចាន់ | ឫទ្ធីឌី |
| ១១ | លោក | គួន់ | តារ៉ា |
| ១២ | លោក | យក់ | យុទ្ធនាការ |

**ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :**

| | | | |
|---|---|---|---|
| ១ | លោក | អ៊ុក | ឃួច |
| ២ | លោក | ជ | ចណ្ណារិទ្ធ |
| ៣ | លោក | ជិន | ម៉ុនលាង |
| ៤ | លោក | ឆាយ | អ៊ែងអ៊ាំង |
| ៥ | លោក | ជួង | សុភា |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រណ.១១០៣.២៤១

ធ្វើនៅព្រះបរមរាជវាំង .ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១១

លេខៈ ២២៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន ជិនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបនការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

## សម្រេច

**មាត្រា១៖**

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ដែនជម្រកសត្វព្រៃលំផាត់ លើផ្ទៃដីទំហំ ៨.៨២៥ (ប្រាំបីពាន់ ប្រាំបីរយ ម្ភៃប្រាំ)ហិកតា ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកលំផាត់ ខេត្តរតនៈគីរី សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ដូនពេញ អាហ្គ្រីកូ** (DAUN PENH AGRICO Co., Ltd) ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ២៤១ សជណ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១១ ជាឧបសម្ព័ន្ធ។

**មាត្រា២៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនៈគីរី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិនា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
  "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ផែនទី ទីតាំងវិនិយោគអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មរបស់ក្រុមហ៊ុន ដូនពេញ អាគ្រីកូ ខូ អិលធីឌី (DAUN PENH AGRICO Co.,Ltd)
ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃលំផាត់ ភូមិសាស្ត្រស្រុកលំផាត់ ខេត្តរតនគិរី លើផ្ទៃដីចំនួន ៨៨២៥ ហិកតា ក្នុងទីតាំងរួមក្នុងដែនដីទំហំ ៩៨០៥ ហិកតា




| Id | N | Coor_x | Coor_y |
|---|---|---|---|
| 1 | A | 700460 | 1485052 |
| 2 | B | 704305 | 1487930 |
| 3 | C | 703680 | 1491156 |
| 4 | D | 704881 | 1491176 |
| 5 | E | 706087 | 1489151 |
| 6 | F | 708000 | 1490000 |
| 7 | G | 714000 | 1490000 |
| 8 | H | 717309 | 1488352 |
| 9 | I | 718240 | 1486576 |
| 10 | J | 719709 | 1481989 |
| 11 | K | 715104 | 1481982 |
| 12 | L | 712800 | 1484000 |
| 13 | M | 706000 | 1484000 |
| 14 | N | [illegible]39 | 1482170 |

ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ............
ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ២០១១
ជ. ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ............ស.ជ.ណ
ធ្វើនៅថ្ងៃទី ...... ខែ ...... ឆ្នាំ ២០១១
ជ. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៧៦០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

### សម្រេច

**មាត្រា ១.-**

